**អត្ថបទវិចារណកថា**

*វ៉ុល២, លេខ៤, ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០*

# *កូវីដ១៩៖ ទស្សនវិជ្ជាមនុស្ស តួនាទីរបស់រដ្ឋាភិបាល និងការកសាងជាតិ*

លោកបណ្ឌិត អ៊ុន លាង*

ក្នុងពេលបច្ចុប្បន្ននេះ ស្ថានភាពនៃជំងឺកូវីដ១៩ បង្កើតបានជាកាលានុវត្តភាពដ៏សុក្រឹតបំផុតសម្រាប់ការពិភាក្សាអំពីបញ្ហាស្នូលនៃទស្សនវិជ្ជាមនុស្សជុំវិញសីលធម៌នៃការរស់រានមានជីវិត និងតួនាទីរបស់រាជរដ្ឋាភិបាលក្នុងការចាត់ចែងសង្គមជាតិ និងការកសាងជាតិ។ ការជជែកពិភាក្សានេះ មិនមានបំណងបង្វែរប្រធានបទឲ្យទៅជាការអង្កេតផ្នែកនយោបាយផ្សេងៗ ដូចជាសំណួរថា តើប្រភពនៃមេរោគចេញពីទីណា? ឬថាតើអ្នកណាគួរតែត្រូវបានស្តីបន្ទោស ឬថាតើអ្នកណាគួរតែជាអ្នកទទួលខុសត្រូវលើបញ្ហានៃការរីករាលដាលនៃមេរោគនេះ? ឬមួយក៏ទាក់ទងទៅនឹងទ្រឹស្តីដែលមិនទាន់ច្បាស់លាស់ណាមួយ ដែលបានធ្វើសម្មតិកម្មថា តើមេរោគនេះ គឺជាការវិវត្តតាមបែបធម្មជាតិ ឬជាការបង្កើតឡើងរបស់មនុស្ស?

គោលបំណងនៃការពិភាក្សានៅទីនេះ គឺផ្តោតលើទិ្វកភាពផ្នែកសីលធម៌ទាក់ទងទៅនឹងការព្យាយាមបញ្ចប់ការរីករាលដាលនៃមេរោគក្នុងរបៀបមួយដែលប្រសើរបំផុតដែលត្រូវធ្វើឡើងដោយរាជរដ្ឋាភិបាល និងដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើម្បីធានាឲ្យបាននូវវិបុលភាព និងសុខភាពមនុស្សជាតិ និងការពិចារណាទៅលើការបាត់បង់ជីវិតមនុស្សក្នុងគ្រាអាសន្ននេះ និងយុទ្ធសាស្រ្តកសាងជាតិក្រោយពេលស្ថានភាពនៃវិបត្តិនេះបានបញ្ចប់ទៅវិញ។

នៅជុំវិញពិភពលោក ជាពិសេសបណ្តាប្រទេសជឿនលឿន និងរីកចម្រើន អ្នកជំនាញបានផ្តល់នូវជម្រើសបួនប្រភេទ។ ជម្រើសទី១៖ ការលុបបំបាត់មេរោគ, ជម្រើសទី២៖ ការលុបបំបាត់ខ្សែកោង, ជម្រើសទី៣៖ ការបន្ទាបខ្សែកោងដើម្បីបង្កើនភាពស៊ាំនៃរាងកាយ និងជម្រើសទី៤៖ ការបង្កើនភាពស៊ាំនៃរាងកាយតាមរយៈជម្រើសធម្មជាតិ ដែលប្រហែលជាជម្រើសមួយមិនសូវមានការគាំទ្រច្រើន ហើយក៏ពិបាកនឹងគិតដល់ដែរ។

### ❖ ជម្រើសទី១៖ ការលុបបំបាត់មេរោគ

ជម្រើសនេះ ទាក់ទងទៅនឹងការបិទចរាចរណ៍យ៉ាងតឹងរឹងបំផុត ក្នុងចន្លោះពី៦សប្តាហ៍ ទៅ៣ខែ។ ប្រទេសចិន បានអនុវត្តជម្រើសនេះមុនដំបូងគេនៅទីក្រុងវូហាន ខេត្តហ៊ូប៉ី ជាទីដែលមេរោគនៃជំងឺកូវីដ១៩ បានកើតឡើងដំបូងគេ មុនពេលដែលមេរោគនេះបន្តសាយភាយនៅជុំវិញពិភពលោក។ ក្នុងពេលបច្ចុប្បន្ន ការបិទតំបន់តូចមួយហាក់ដូចជាហួសពេលទៅហើយ នៅពេលដែលវត្តមាននៃអ្នកឆ្លងមេរោគនេះមិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ និងហាក់ដូចជានៅពាសពេញគ្រប់ទីកន្លែង។

ប្រទេសដែលមានបំណងអនុវត្តជម្រើសនេះ ត្រូវតែពង្រីកទៅដល់កម្រិតសហគមន៍ធំ ដែលក្នុងនោះប្រជាជននឹងមិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីសហគមន៍ដែលខ្លួនរស់នៅនោះ

*__លោកបណ្ឌិត អ៊ុន លាង__ គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្រ្តនិងមនុស្សសាស្រ្តនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

ទេ សូម្បីតែធ្វើការហាត់ប្រាណ ឬទិញទំនិញផ្សេងៗ។ ការបិទចរាចរណ៍នេះ នឹងនាំឲ្យមានការបង្រួមការចម្លងមេរោគឲ្យនៅកម្រិតតំបន់តូចមួយ ហើយអាជ្ញាធរមានភាពងាយស្រួលក្នុងការតាមដាន។ ប្រសិនបើអនុវត្តវិធានការនេះ ជាវិបាក តំបន់ ឬប្រទេសទាំងមូល នឹងស្ថិតនៅក្នុងភាពនឹងថ្កល់ ដោយមិនមានការងារធ្វើ និងមិនមានអ្វីកើតឡើងទាំងអស់ ក្រៅតែអំពីការផ្គត់ផ្គង់ចំណីអាហារ។ អ្នកទាំងឡាយណាដែលលេចចេញនូវរោគសញ្ញានៃការឆ្លងមេរោគ នឹងត្រូវចាប់បង្ខាំងទុក ហើយធ្វើការព្យាបាលតាមលទ្ធភាព និងសមត្ថភាពនៃប្រព័ន្ធសុខាភិបាល និងឯកទេសវេជ្ជសាស្ត្ររបស់ប្រទេសនីមួយៗ។ ការណ៍នេះ ត្រូវតែបានតាមដានយ៉ាងតឹងរឹងបំផុតប្រហែល ១៨ខែ (អាចតិច ឬច្រើនជាងនេះ) រហូតដល់មានវ៉ាក់សាំងការពារមេរោគត្រូវបានដាក់ឲ្យប្រើប្រាស់។ ព្រំដែនតំបន់ ឬប្រទេស នឹងនៅតែត្រូវបានបិទទាំងស្រុងដើម្បីការពារកុំឲ្យមានការនាំចូលមេរោគថ្មីពីខាងក្រៅ។ ជម្រើសទី១នេះ គឺជាជម្រើសដែលពិបាកនឹងអនុវត្តបំផុត ហើយបើអាចអនុវត្តបាន លុះត្រាតែមានឆន្ទៈនយោបាយដាច់ខាត និងកងកម្លាំងសន្តិសុខគ្រប់គ្រាន់។

### ❖ ជម្រើសទី២៖ ការលុបបំបាត់ខ្សែកោង

នេះជាអ្វីដែលបានកំពុងកើតឡើង ក្នុងកម្រិតទំនាក់ទំនងរវាងប្រទេសមួយទៅនឹងប្រទេសមួយទៀត រវាងរដ្ឋ ឬខេត្តមួយទៅរដ្ឋ ឬខេត្តមួយទៀត រួមមានការបិទប្រទេស ឬរដ្ឋ ឬខេត្តទាំងស្រុង ការបិទអាកាសយានដ្ឋាន និងដាក់កម្រិតតឹងរឹងលើការធ្វើដំណើរ ដូចជាលិខិតបញ្ជាក់ថាគ្មានផ្ទុកមេរោគដែលបង្កជំងឺកូវីដ១៩ និងប័ណ្ណធានារ៉ាប់រងសុខភាព ជាពិសេសការធ្វើដំណើរឆ្លងប្រទេស។ ប៉ុន្តែលទ្ធផល គឺថាប្រហែលជាត្រូវការការបិទចរាចរណ៍យូរជាងអ្វី ដែលចេញដោយរដ្ឋាភិបាល ឬអាជ្ញាធរក្នុងពេលបច្ចុប្បន្ននេះ ពីព្រោះថាមិនមានអ្វីអាចស្តារស្ថានភាពបានទេ រហូតដល់មានវ៉ាក់សាំងការពារមេរោគ។

គេបានប៉ាន់ស្មានថា វានឹងមានតែ២ ទៅ៥ភាគរយនៃចំនួនប្រជាជនតែប៉ុណ្ណោះ ដែលនឹងឆ្លងមេរោគនេះក្នុងកម្រិតខ្ពស់បំផុត[1]។ ប៉ុន្តែវានឹងតម្រូវឲ្យមនុស្សយ៉ាងតិចបំផុត ៨០% នៅក្នុងផ្ទះ[2]។ ក្នុងរយៈពេលខ្លី រដ្ឋាភិបាលកំពុងបញ្ចេញកញ្ចប់ថវិកាជួយសង្គ្រោះទាំងកម្រិតក្រុមហ៊ុន បុគ្គល និងគ្រួសារ ប៉ុន្តែតាមលក្ខណៈសេដ្ឋកិច្ច ក្នុងរយៈពេលវែង វានឹងមិនមានចីរភាពនោះទេ។

### ❖ ជម្រើសទី៣៖ បន្ទាបខ្សែកោងដើម្បីបង្កើនភាពស៊ាំនៃរាងកាយ

ដោយគ្មានវ៉ាក់សាំង ការបង្កើនភាពស៊ាំនៃរាងកាយត្រូវបានគេចាត់ទុកថា ជាវិធីមួយដែលអាចធ្វើទៅបាន ដើម្បីកំចាត់មេរោគ។ ជម្រើសនេះ ក៏នៅតែត្រូវការការបិទចរាចរណ៍ផ្នែកខ្លះរយៈពេល៦ខែ ប៉ុន្តែរយៈពេលនេះ វាអាស្រ័យទាំងស្រុងថាតើរដ្ឋាភិបាល បានត្រៀមខ្លួនប្រថុយប្រថានបែបណាជាមួយផលវិបាកដែលអាចនឹងកើតមានឡើងពីការបិទចរាចរណ៍ដ៏យូរបែបនេះ។

ជាវិបាកដ៏ចាំបាច់ គឺថាការឆ្លងមេរោគវាអាចកើនឡើងក្នុងចំនួនមួយ តែគេត្រូវកំណត់ត្រឹមចំនួនមួយដែលអាចគ្រប់គ្រងបាន ជាទូទៅរហូតដល់ត្រឹមប្រហែលជា៦០% (ភាគរយនេះប្រែប្រួលពីចន្លោះ ៤០% ទៅ៩៥%) នៃចំនួនប្រជាជនដែលបានឆ្លងជំងឺកូវីដ១៩ ចំណុចដែលអាចនាំមកនូវភាពស៊ាំនៃរាងកាយ ហើយវាធ្វើឲ្យមេរោគលំបាកក្នុងការរីករាលដាលបន្តទៀត។ ទោះបីជាមានកូនក្មេងខ្លះ អាចស្លាប់ដោយជំងឺ

[1] នៅរដ្ឋញូវយ៉ក សហរដ្ឋអាមេរិក ជាពិសេសទីក្រុងញូវយ៉ក ដែលមានកម្រិតឆ្លងលឿន និងស្លាប់ច្រើនហួសជាងគេ មានអ្នកឆ្លងមិនដល់ ១% នៃប្រជាជនសរុបផង។
[2] អ្នកមានភារកិច្ចចាំបាច់ក្នុងការធ្វើឲ្យប្រទេស ឬរដ្ឋ ឬខេត្តមួយមានអត្ថិភាព និងដំណើរការនៅតែចរាចរបាន។

កូវីដ១៩ក៏ដោយ អ្នកដែលនឹងត្រូវស្លាប់ច្រើនជាងគេពីមេរោគនេះ ភាគច្រើនគឺជាមនុស្សចាស់ ហើយពួកគាត់ប្រហែលជាស្ថិតក្នុងស្ថានភាពសុខភាពមួយ ដែលមិនប្រសើររួចជាស្រេចទៅហើយ។ ចំនួនអ្នកស្លាប់ពិតប្រាកដ វាអាស្រ័យទាំងស្រុងទៅលើសមត្ថភាព និងឯកទេសវេជ្ជសាស្ត្រនៃប្រព័ន្ធសុខាភិបាលនៃប្រទេសនីមួយៗ។

យុវជន និងមនុស្សដែលមានសុខភាពល្អ នឹងត្រូវត្រៀមខ្លួនក្នុងការឆ្លងមេរោគនេះ។ ការការពារខ្លួនមិនឲ្យឆ្លង គឺជាការសម្រេចចិត្ត និងការកែប្រែទម្លាប់រស់នៅរបស់បុគ្គល ហើយវាអាស្រ័យតាមធនធានដែលខ្លួនមាន ឬធនធានដែលរដ្ឋាភិបាលមានក្នុងការជួយពួកគេ។

### ❖ ជម្រើសទី៤៖ ការបង្កើនភាពស៊ាំនៃរាងកាយតាមរយៈជម្រើសធម្មជាតិ

ជម្រើសទី៤ ជាជម្រើសមួយដែលប្រហែលជាមិនមានមនុស្សច្រើនគាំទ្រនោះទេ ឬក៏មិនមានមនុស្សច្រើនទេដែលគិតពីជម្រើសនេះ។

ការវិលត្រឡប់ទៅកាន់ជីវិតដូចដែលមិនទាន់មានជំងឺកូវីដ១៩ ប៉ុន្តែកាល និងលំហពេលនេះ តម្រូវឲ្យមនុស្សរៀនសូត្រ និងពង្រឹងបន្ថែមការអនុវត្តអនាម័យរស់នៅបែបថ្មី ហើយ "ការនៅឲ្យឆ្ងាយពីទំនាក់ទំនងក្នុងសង្គមមនុស្ស" ត្រូវតែដាក់ឲ្យអនុវត្តស្របពេលដែលយើងត្រូវកំណត់អត្តសញ្ញាណអ្នកឆ្លងមេរោគ ហើយដាក់ពួកគេឲ្យនៅដាច់ដោយឡែក និងព្យាបាលរហូតដល់ពួកគេជា ឬដល់ស្លាប់ប្រសិនបើអស់លទ្ធភាពព្យាបាល។ ចំនួនអ្នកស្លាប់តិច ឬច្រើន វាអាស្រ័យលើសមត្ថភាពរបស់ប្រទេស ឬតំបន់នីមួយៗ ក្នុងការកំណត់អត្តសញ្ញាណអ្នកផ្ទុកមេរោគដែលបង្កជំងឺកូវីដ១៩ និងសមត្ថភាពបង្ខាំង ឬដាក់អ្នកមានផ្ទុកមេរោគឲ្យនៅដាច់ដោយឡែកពីគេ។

យ៉ាងណាក៏ដោយ ជម្រើសនេះនឹងនាំមកនូវលទ្ធផលដែលមិនអាចចៀសបាន នោះគឺអាចមានមនុស្សស្លាប់ច្រើនពីជំងឺកូវីដ១៩ ប៉ុន្តែចំនួននេះ នឹងមានតិចជាងការស្លាប់ដោយប្រយោល ដោយសារវត្តមាននៃកូវីដ១៩ ដូចជាភាពអត់ឃ្លាន វិបត្តិសង្គមដែលចេញមកពីការដួលរលំនៃសេដ្ឋកិច្ច និងការបន្ទោសរដ្ឋាភិបាលថាបានចាត់ចែងដំណោះស្រាយខុស ប្រសិនបើមិនមានការរកឃើញវ៉ាក់សាំងឲ្យបានឆាប់ៗ និងចែកចាយឲ្យបានទាន់ពេលវេលា ជាពិសេសទៅដល់ប្រទេសក្រីក្រ។

ជម្រើសណាមួយក៏ដោយ វាទាក់ទងទៅនឹងទស្សនវិជ្ជាមនុស្ស នោះគឺមានន័យថា ត្រឹមកម្រិតចំនួនណាដែលមនុស្សអាចនឹងត្រូវឆ្លងមេរោគ និងជាពិសេសអ្នកណាដែលនឹងត្រូវស្លាប់ និងដោយរបៀបណា?

### ❖ កម្ពុជានៅទីណាក្នុងវិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ១៩?

ស្ថានភាពនៅកម្ពុជា មិនទាន់ដល់កម្រិតប្រកាសអាសន្ននៅឡើយទេ។ គិតមកត្រឹមថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ នេះ មានអ្នកឆ្លងជំងឺកូវីដ១៩ មានត្រឹមតែ ១២២នាក់ ប៉ុណ្ណោះ មិនមានអ្នកស្លាប់ណាម្នាក់ទេ ហើយអ្នកជាសះស្បើយមានចំនួនរហូតដល់ ៧៧នាក់។ ទោះបីជាយ៉ាងនេះក៏ដោយ កម្ពុជាមានការប្រុងប្រយ័ត្នខ្ពស់បំផុត មិនត្រឹមតែការចាត់ចែងពីសំណាក់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែការចូលរួមពីសំណាក់ប្រជាជនផងដែរ។ កម្ពុជាហាក់កំពុងអនុវត្តជម្រើសចម្រុះក្នុងការការពារការរីករាលដាលនៃជំងឺកូវីដ១៩។ កម្ពុជាក៏បានខិតខំប្រែក្លាយស្ថានភាពវិបត្តិនេះ ឲ្យទៅជាឱកាសមាសមួយ ដោយបានបំលែងឧស្សាហកម្មវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងស្បែកជើងរបស់ខ្លួនទៅជារោងចក្រផលិតជាម៉ាសសម្រាប់ការពារ ហើយនិងបានប្រែក្លាយរោងចក្រផលិតស្រាបៀរឲ្យ

ផលិតអាល់កុលសម្រាប់សម្លាប់មេរោគ ក្នុងកិច្ចប្រឹងប្រែងការពារការរីករាលដាលនៃជំងឺកូវីដ១៩។

## ឈប់ ឈប់មួយភ្លែតសិន!

នៅទីនេះ អនុញ្ញាតឲ្យខ្ញុំផ្អាកការជជែកអំពីបញ្ហាការការពារ និងការរីករាលដាលនៃជំងឺកូវីដ១៩ មួយភ្លែតសិន។

ការស្រាវជ្រាវមួយធ្វើឡើងដោយក្រុមហ៊ុនមួយ ដែលមានមូលដ្ឋាននៅប្រទេសអង់គ្លេសបានរកឃើញថា ក្នុងឆ្នាំ២០១៩ ប្រទេសចំនួន៤៧ ក្នុងចំណោមប្រទេស១៩៥ (រាប់បញ្ចូលទាំងបូរីវ៉ាទីកង់ និងប៉ាឡេស្ទីន) មានការកើតឡើងនូវភាពចលាចលក្នុងសង្គម។ ក្រុមហ៊ុននេះ ក៏បានធ្វើការទស្សន៍ទាយតាមរយៈគំរូម៉ូឌែលរបស់ខ្លួនថា នៅឆ្នាំ២០២០ ចំនួនប្រទេសដែលនឹងកើតមានភាពចលាចល និងការប្រេះឆានៃស្ថិរភាពសង្គមនឹងកើនដល់ចំនួន៧៥ក្នុងចំណោមប្រទេសតែ១២៥។ នេះមានន័យថា ៤០% ក្នុងចំណោមប្រទេសទាំង១៩៥ នឹងជួបវិបត្តិបែបនេះ[3]។ ថ្មីៗនេះ នៅកម្រិតសាកលលោកទាំងមូល នៅពេលដែលមានការកើនឡើងនៃចំនួនអ្នកឆ្លងជំងឺកូវីដ១៩ រហូតដល់ជិត១,៨លាននាក់ និងមានអ្នកស្លាប់រហូតដល់ជាង ១០០.០០០នាក់[4] អ្នកវិភាគសង្គម សេដ្ឋកិច្ច និងនយោបាយ បានព្រមព្រៀងគ្នាថា នៅប៉ុន្មានខែខាងមុខនេះ នឹងអាចមានប្រទេសជាច្រើនជួបប្រទះនឹងភាពចលាចលក្នុងសង្គម និងអាចមានការផ្លាស់ប្តូរនយោបាយផងដែរ។

ទោះបីជាមានការសិក្សា និងការអះអាងថា សន្តិភាពនៅកម្ពុជានៅមានលក្ខណៈផុយស្រួយងាយប្រេះឆាក៏ដោយ សន្តិភាពពេញលេញដែលទទួលបានយ៉ាងលំបាកក្នុងឆ្នាំ១៩៩៨ នឹងមិនត្រូវបាត់បង់នោះទេ ជាពិសេសមិនគួរឲ្យកើតមានក្នុងស្ថានភាពដ៏លំបាកនៃការរីករាលដាលជំងឺកូវីដ១៩ នេះទេ។ លើសពីនេះទៀត ការកសាងជាតិមួយ គឺពិតជាហួសពីការឆ្លើយតបទៅនឹងវិបត្តិនៃជំងឺកូវីដ១៩ ហើយការកសាងជាតិមួយរឹងមាំបាន វានឹងអាចដោះស្រាយបានគ្រប់វិបត្តិទាំងអស់នាពេលអនាគត។

## ❖ តើអ្វីជាតួនាទីរបស់រដ្ឋាភិបាល?

ក្នុងន័យនេះ ការកសាងជាតិ ភាពចលាចលក្នុងសង្គម និងការផ្លាស់ប្តូរនយោបាយ គឺជារឿងតែមួយ។ នៅទីនេះ អនុញ្ញាតឲ្យខ្ញុំសាកល្បងសិក្សា ពីមូលហេតុនៃភាពចលាចលក្នុងសង្គម និងការផ្លាស់ប្តូរនយោបាយ ហេតុនេះ មិនបានរួមចំណែកក្នុងការកសាងជាតិមួយ តែបែរជានាំសង្គមជាតិមួយឲ្យបែកបាក់ទៅវិញ។ ការកសាងជាតិ គឺជាការរួបរួមនៃប្រជាជនក្នុងរដ្ឋមួយ ហេតុនេះ រដ្ឋនោះនឹងមានស្ថិរភាពនយោបាយ និងវត្តមានជារហូតនិរន្តរ៍។ នៅក្នុងបេះដូងនៃការកសាងជាតិ គឺកម្មវិធីរបស់រដ្ឋាភិបាល ជាពិសេសវិស័យការពារជាតិ និងសន្តិសុខជាតិ កម្មវិធីសិក្សាធិការជាតិ និងកម្មវិធីវិស្វកម្មសង្គមធំៗដើម្បីពង្រីក និងពង្រឹងភាពសុខដុមក្នុងសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច។ ស្នូលនៃការកសាងជាតិ គឺស្ថិតនៅក្នុងការលេចឡើងនូវសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការផ្តល់ភាពល្អជាសាធារណៈដល់ពលរដ្ឋរបស់ខ្លួននៅទូទាំងប្រទេសប្រកបដោយសមធម៌[5] ដូច្នេះប្រជាពលរដ្ឋទាំងអស់ នឹងចូលរួមកសាងជាតិវិញ។

នៅកម្ពុជា វិស័យការពារជាតិ និងសន្តិសុខជាតិមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ជាពិសេសអ្នកមានបទពិសោធន៍រស់នៅ

---

[3] សូមមើល Reid, D. (January 16, 2020). Almost 40% of the world’s countries will witness civil unrest in 2020, research claims. *CNBC*. យកចេញពី https://www.cnbc.com/2020/01/16/40percent-of-countries-will-witness-civil-unrest-in-2020-report-claims.html, នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

[4] យកចេញពី https://www.worldometers.info/coronavirus/?, នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០។

[5] សូមមើល Wimmer, A. (2018). *Nation Building: Why some countries come together while others fall apart.* Princeton: Princeton University Press.

លើទឹកដីកម្ពុជាផ្ទាល់។ នេះយើងមិននិយាយអំពីអំឡុងពេលសង្គ្រាមស៊ីវិល និងនៅតាមតំបន់ដាច់ស្រយាលនោះទេ សូម្បីនៅទីក្រុងភ្នំពេញក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ សំឡេងគ្រាប់កាំភ្លើងបានលាន់ឮ អំពើចោរប្លន់ និងអំពើចាប់ជំរិតកើតមានស្ទើរគ្មានលោះថ្ងៃណាឡើយ។ បច្ចុប្បន្ន យើងស្ទើរតែមិនឮសំឡេងគ្រាប់កាំភ្លើងនេះទាល់តែសោះ អំពើចោរប្លន់មានការថយចុះគួរឲ្យកត់សម្គាល់ ហើយអំពើចាប់ជំរិតស្ទើរតែគ្មានឮ។

ប៉ុន្តែ ការកសាងជាតិលើវិស័យផ្សេងទៀតមានល្បឿនយឺតជាង។ ទោះបីជាមានការចាប់ផ្តើមខ្លះៗ កម្មវិធីវិស្វកម្មសង្គមធំៗ ដើម្បីពង្រីក និងពង្រឹងភាពសុខដុមក្នុងសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចហាក់មិនទាន់មានចំនួនច្រើននៅឡើយ។ នេះប្រហែលដោយសារតែ ចាប់តាំងពីការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ កម្ពុជាបានបត់បែន និងហាក់ដូចជាបោះបង់ចោលតួនាទីរបស់រដ្ឋក្នុងកិច្ចការនេះ ដោយចាត់ទុកវិស័យឯកជនជាអ្នកដឹកមុខ ក្នុងខណៈដែលរដ្ឋដើរតួនាទីត្រឹមតែជាអ្នកសម្របសម្រួល និងគ្រប់គ្រងយន្តការ និងការងារគតិយុត្តិ[6]។ បើទោះបីជារាជរដ្ឋាភិបាលខិតខំពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់ភាពល្អជាសាធារណៈដល់ពលរដ្ឋរបស់ខ្លួននៅទូទាំងប្រទេស ប្រកបដោយសមធម៌យ៉ាងណាក៏ដោយ ការណ៍ដែលចាត់ទុកវិស័យឯកជនជាស្នូលនៃដំណើរការអភិវឌ្ឍសេដ្ឋកិច្ច មិនបានបង្រួមគម្លាតរវាងអ្នកមាន និងអ្នកក្រនោះទេ ហើយគម្លាតនៃអំណាចទិញដើម្បីឲ្យមានជីវភាពរស់នៅសមរម្យ និងថ្លៃថ្នូរក៏មិនមានប្រហាក់ប្រហែលគ្នាក្នុងចំណោមពលរដ្ឋទាំងអស់ដែរ ជាពិសេសរវាងអ្នកជនបទ និងអ្នកទីក្រុង[7]។

ស្ថានភាពប្រសើរឡើង ដែលមើលឃើញនៅតាមទីជនបទបានបញ្ជាក់ពីការដើរតួនៃវិស័យឯកជន ជាជាងតួនាទីរបស់រដ្ឋ ជាពិសេសតាមរយៈការរីកលូតលាស់នៃវិស័យមីក្រូហិរញ្ញវត្ថុ និងការផ្ញើថវិកាត្រឡប់មកវិញ ដោយកម្មករចំណាកស្រុកខ្មែរដែលធ្វើការងារនៅក្រៅប្រទេស។ ក្នុងឆ្នាំ២០១៩ កម្មករចំណាកស្រុកខ្មែរចំនួន១,២លាននាក់ ដែលធ្វើការនៅប្រទេសថៃ កូរ៉េខាងត្បូង ជប៉ុន សិង្ហបុរី ហុងកុង និងសូវឌីអារ៉ាប៊ី បានផ្ញើថវិកាសរុបចំនួន ២៨០០លាន ដុល្លាសហរដ្ឋអាមេរិចត្រឡប់មកកម្ពុជាវិញ[8]។ នេះមិនរាប់បញ្ចូលចំនួនអ្នកធ្វើការងារខុសច្បាប់នៅប្រទេសថៃ ដែលមានការប៉ាន់ប្រមាណថា មានចំនួនប្រហែល២លាននាក់ ទាំងត្រូវច្បាប់ និងខុសច្បាប់[9] ហើយនេះក៏មិនរាប់បញ្ចូលនូវជនជាតិខ្មែរ ដែលរស់នៅប្រទេសធំៗដូចជាសហរដ្ឋអាមេរិច បារាំង អូស្ត្រាលី ញ៉ូហ្សេឡែន ដែលមានទំនាក់ទំនងខាងសេដ្ឋកិច្ចដ៏ច្រើនជាមួយប្រជាជនក្នុងស្រុកផងដែរ។ គ្មានប្រទេសណាមួយ ដែលកម្មករខ្មែរយើងទៅធ្វើការមិនទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩នោះទេ រួមទាំងប្រទេសធំៗ ដែលមានជនជាតិខ្មែររស់នៅច្រើនផងដែរ។ នេះមានន័យថា ការរីកចម្រើននៅជនបទនឹងមានការរង្គោះរង្គើ ទោះតិចឬច្រើន រយៈពេលខ្លីឬវែង។

មួយផ្នែកធំនៃការរីកលូតលាស់នៃវិស័យមីក្រូហិរញ្ញវត្ថុនៅជនបទ គឺផ្អែកលើសរសរស្តម្ភនៃការរីកចម្រើននៅថ្នាក់ជាតិ

[6] ដូចដែលមានបញ្ជាក់នៅក្នុងផែនការស្តារ និរអភិវឌ្ឍសេដ្ឋកិច្ចសង្គមលើកទី១ និងយុទ្ធសាស្ត្រត្រីកោណ និងចតុកោណជាបន្តបន្ទាប់ និងផែនការអភិវឌ្ឍជាតិជាហូរហែរ។

[7] ការអះអាងបែបនេះ មិនមែនមានន័យថា យើងទាត់ចោលតួនាទីរបស់វិស័យឯកជនក្នុងដំណើរការអភិវឌ្ឍនោះទេ ប៉ុន្តែអនុញ្ញាតឲ្យយើងពិនិត្យឡើងវិញពីកម្រិត និងប្រភេទនៃការចូលរួមរបស់វិស័យឯកជន។

[8] សូមមើល Chea Vannak. $2.8 Billion sent home by Cambodian migrant workers in 2019. Khmer Times, February 28, 2020. យកចេញពី https://www.khmertimeskh.com/50696319/2-8-billion-sent-home-by-cambodian-migrant-workers-in-2019, នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

[9] យកចេញពី https://www.bangkokpost.com/world/1881345/cambodian-workers-told-not-to-leave-thailand-amid-covid-19-fears, នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

ដែលស្រូបយកកម្លាំងពលកម្មចេញពីទីនោះផងដែរ ដូចជាវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ទេសចរណ៍ និងសំណង់។ ទោះបីជាវិស័យសំណង់ មិនទាន់ត្រូវបានរាយការណ៍ថាមានផលប៉ះពាល់ខ្លាំងពីការរីករាលដាលនៃជំងឺកូវីដ១៩ ក៏ដោយ វិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និងវិស័យទេសចរណ៍កំពុងរងសម្ពាធយ៉ាងខ្លាំងបំផុត។ កត្តានេះ នឹងដាក់សម្ពាធលើរបៀបដែលតំបន់ជនបទនៅកម្ពុជា ដែលមានការរីកចម្រើនកន្លងមក ហេតុនេះ ទោះតិចឬច្រើន រយៈពេលខ្លីឬវែង សេដ្ឋកិច្ចនៅជនបទនឹងមានការរង្គោះរង្គើរ។

ជាទូទៅ កសិកម្មកើតមាននៅតាមតំបន់ជនបទ ដែលជាស្នូលនៃការរីកចម្រើននៅជនបទ។ នៅកម្ពុជា វិស័យកសិកម្មរហូតមកទល់ពេលនេះនៅតែជាសរសរស្តម្ភមួយ ក្នុងចំណោមសរសរស្តម្ភទាំង៤[10] នៃសេដ្ឋកិច្ចរបស់ខ្លួន។ ប៉ុន្តែ កសិកម្មនៅកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលដំបូងនៃរបត់រីកចម្រើននៅឡើយ នោះគឺដោយសារការវិនិយោគនៅមានកម្រិតតិចតួច ហើយផលិតភាពនៅទាប បើប្រៀបធៀបជាមួយប្រទេសនានាក្នុងតំបន់។ អ្វីដែលគួរឲ្យចាប់អារម្មណ៍បំផុតនោះ គឺកង្វះឧស្សាហកម្មចំណីអាហារ។ ៩០% នៃកសិផលដែលប្រទេសកម្ពុជានាំចេញ គឺពុំមានការឆ្លងកាត់ឧស្សាហកម្មក្នុងស្រុកនោះទេ (ដូចជាស្វាយចន្ទី ស្វាយ កៅស៊ូ និងដំឡូងមី) ជាពិសេសទៅប្រទេសថៃ និងប្រទេសវៀតណាម ដែលមានរោងចក្រឧស្សាហកម្ម ហើយបានចំណេញពីកម្ពុជាច្រើន។

អ្វីដែលពិបាកជឿបំផុតនោះគឺ នៅពេលដែលកម្ពុជានៅតែផ្អែកលើកសិកម្ម និងមានចំនួនប្រជាជនប្រហែល ៣០% ប្រកបរបរកសិកម្ម កម្ពុជានៅពុំអាចដាំដុះផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងស្រុកសម្រាប់បម្រើតម្រូវការទទួលទានប្រចាំថ្ងៃរបស់ប្រជាជនខ្លួន ដូចជាត្រី សាច់ បន្លែ និងផ្លែឈើជាដើម។ បញ្ហានេះ ជាប្រការមួយនាំឲ្យកម្ពុជាបង្ខំចិត្តនាំចូលពីបរទេស ជាពិសេសពីប្រទេសជិតខាងកម្ពុជា ដើម្បីមកបំពេញសេចក្តីត្រូវការរបស់ពលរដ្ឋខ្លួន។ នេះប្រហែល បណ្តាលមកពីកង្វះការយកចិត្តទុកដាក់ទៅលើពូជ និងបច្ចេកវិទ្យាកសិកម្ម បន្ថែមពីលើកង្វះទុនវិនិយោគដូចបានរៀបរាប់ខាងលើ។ រហូតមកទល់ឆ្នាំ ២០១៩ ទើបកម្ពុជាដាក់ចេញយុទ្ធសាស្ត្រពូជជាតិលើកទី១ ហើយបច្ចេកវិទ្យាកសិកម្មជាទូទៅនៅមានកម្រិតទាប។ នៅពេលដែលការរីករាលដាលនៃជំងឺកូវីដ១៩ កាន់តែមានសភាពខ្លាំងឡើងៗ ជាពិសេសនៅប្រទេសថៃ និងវៀតណាម ដែលកំពុងទទួលរងគ្រោះធ្ងន់ធ្ងរជាងកម្ពុជាស្រាប់ទៅហើយនោះ ផលិតផលកសិកម្មសម្រាប់បម្រើការដល់ការទទួលទានប្រចាំថ្ងៃនៅកម្ពុជានឹងជួបវិបត្តិ ទោះតិចឬច្រើន និងរយៈខ្លីឬវែង។

ការពង្រីកឧស្សាហកម្មពីទាបទៅមធ្យម និងទៅខ្ពស់ ជាពិសេសឧស្សាហកម្មសម្រាប់គាំទ្រជីវិត ដូចជាក្នុងវិស័យវេជ្ជសាស្ត្រកំពុងជួបឧបសគ្គ មិនគ្រាន់តែបញ្ហាការកៀរគរវិនិយោគទុនទាំងក្នុងស្រុក និងបរទេសប៉ុណ្ណោះទេ តែកង្វះបច្ចេកវិទ្យា និងធនធានមនុស្សសមស្រប គឺជាបញ្ហាស្នូលផងដែរ។ មាននិស្សិតចំនួនតែ ២,៨៨% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀនផ្នែកវិស្វកម្ម ឧស្សាហកម្ម និងសំណង់[11]។ ការបង្កើនផលិតភាពឧស្សាហកម្ម និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេសការអនុវត្តគោលនយោបាយអភិវឌ្ឍឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ នៅមានកម្រិត និងល្បឿនយឺតនៅឡើយ បន្ថែមពីលើនេះ វានឹងត្រូវពន្យាដោយសារផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩។

[10] សរសរស្តម្ភ៣ទៀត គឺទេសចរណ៍ សំណង់និងអចលនទ្រព្យ និងកាត់ដេរដែលកំពុងរងវិបត្តិពីការរីករាលដាលនៃជំងឺកូវីដ១៩។

[11] យកចេញពី https://tradingeconomics.com/cambodia/, នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

ក្នុងរូបភាពបច្ចុប្បន្ន កម្ពុជាអាចគ្រប់គ្រង និងចាត់ចែងការរីករាលដាលនៃជំងឺកូវីដ១៩។ កត្តានេះ ទទួលបានតាមរយៈការចាត់ចែង និងវិធានការរបស់រាជរដ្ឋាភិបាល និងការចូលរួមពីសំណាក់ពលរដ្ឋទាំងកម្រិតចូលរួមបង្ការការរីករាលដាល និងការចូលរួមជាធនធាន តាមរយៈការអំពាវនាវរបស់ថ្នាក់ដឹកនាំកំពូល។ ប៉ុន្តែនិយាយជារួម តិចឬច្រើន រយៈខ្លីឬវែង សេដ្ឋកិច្ចកម្ពុជា នឹងទទួលឥទ្ធិពលពីការរីករាលដាលនៃជំងឺកូវីដ១៩ ទោះបីក្រោយពេលដែលគ្រោះអាសន្ននេះបានបញ្ចប់ទៅវិញក៏ដោយ។ នេះពីព្រោះតែប្រទេសផ្សេងទៀត ក៏នឹងប្រឹងប្រែងក្នុងការស្តារសេដ្ឋកិច្ចរបស់ខ្លួនដូចគ្នា ដែលនាំឲ្យការប្រកួតប្រជែងកាន់តែមានសន្ទុះខ្លាំងក្លាឡើង។

អ្វីមួយដែលច្បាស់លាស់នោះ គឺយើងពិនិត្យឃើញថា គ្រោះមហន្តរាយដែលបណ្តាលមកពីជំងឺកូវីដ១៩ បានធ្វើឲ្យមានការរង្គោះរង្គើរួចជាស្រេចនូវអ្វីដែលគេជឿជាក់ថា មិនអាចដើរថយក្រោយបាននៃចរន្តតំបន់នីយកម្មនិយម សកលភាវូបនីយកម្មនិយម លំហូរមនុស្ស និងទំនិញដោយសេរី។ល។ ជាជំហរបុគ្គល ខ្ញុំនៅតែជឿជាក់ដូចដែលលោក Thomas R. McFaul បានលើកឡើង គ្រប់សង្គមទាំងអស់នៅតែបន្តការជំនះប្រឹងប្រែងដើម្បីសម្រេចឲ្យបានសុខុមាលភាពសេដ្ឋកិច្ច និងស្ថិរភាពនយោបាយជាអតិបរមាជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន[12]។

ក្នុងន័យនេះ តើអ្វីជាមូលហេតុនៃកង្វះខាតក្នុងការប្រឹងប្រែងស្វែងរកសុខុមាលភាពសេដ្ឋកិច្ចកម្ពុជា នៅពេលដែលកម្ពុជាហាក់សម្រេចបានស្ថិរភាពនយោបាយក្នុងរយៈពេលជិត២០ឆ្នាំចុងក្រោយនេះ?

ប្រហែលជាមូលហេតុចម្បងមួយ ក្នុងចំណោមមូលហេតុនានា គឺបរាជ័យក្នុងវិស័យសិក្សាធិការអប់រំ។ ទោះបីជាមានការមិនយល់ស្របទាំងស្រុងជាមួយរបៀប ដែលរបាយការណ៍អំពីកម្មវិធីសម្រាប់វាយតម្លៃសិស្សជាអន្តរជាតិដើម្បីអភិវឌ្ឍន៍ (ហៅកាត់ថា PISA-D) ធ្វើឡើងក៏ដោយ[13] ក៏របាយការណ៍ឆ្នាំ២០១៨ នេះបានគោះជួងឮៗប្រាប់យើងថា យុវជនកម្ពុជាអាយុ១៥ឆ្នាំ កំពុងជួបវិបត្តិក្នុងការរៀនសូត្រ។ តាមរបាយការណ៍នេះ កម្ពុជាមានចំនួនភាគរយខ្ពស់បំផុតដែលស្ថិតនៅក្រោមកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញខាងអំណាន(៩២%) គណិតវិទ្យា (៩០%) និងវិទ្យាសាស្ត្រ (៩៥%)[14]។ យោងតាមលទ្ធផលនេះ គេអាចសន្មតថា ការអប់រំនៅថ្នាក់បឋមសិក្សាមិនមានគុណភាពគ្រប់គ្រាន់សម្រាប់ជាគ្រឹះនៃការអប់រំកម្រិតមធ្យមសិក្សា ហើយការអប់រំកម្រិតមធ្យមសិក្សានេះមិនមានគុណភាពគ្រប់គ្រាន់សម្រាប់ជាគ្រឹះនៃការអប់រំឧត្តមសិក្សា ហើយការអប់រំឧត្តមសិក្សាមិនមានគុណភាពគ្រប់គ្រាន់សម្រាប់ផលិតមនុស្សទៅបង្រៀននៅកម្រិតក្រោមបានផងដែរ[15]។

---

[12] សូមមើល Thomas R. McFaul) 2010.( The Future of Truth and Freedom in the Global Village: Modernism and the Challenges of the Twenty-first Century, Santa Barbara: ABC- CLIO, LLC, p.159។

[13] សូមមើល Euan Auld, Jeremy Rappleye & Paul Morris (2018). PISA for Development: how the OECD and World Bank shaped education governance post-2015, Comparative Education, DOI: 10.1080/03050068.2018.1538635; Auld, E., and P. Morris. 2016. "PISA, Policy and Persuasion: Translating Complex Conditions into Education 'Best Practice'." Comparative Education 52 (2): 202–229។

[14] សូមមើល MoEYS. (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development.* Phnom Penh: MoEYS។

[15] ដើម្បីស្វែងយល់ពីការអប់រំគ្រូបង្រៀននៅកម្ពុជា សូមមើលរបាយការណ៍មួយចំនួនដូចជា Sot, V., Sok, S. and Dickinson, G. (2019). Four Decades of Teacher Development: Teacher Preparation and Teacher Upgrading Programs in Cambodia from 1979 to 2018, Cambodia Education Review, 3(1), 117-147; Un, L. et al. (2020). Sustainable Development Models in Cambodia and the Republic of Korea: Social Policy and its Financing Policy Under the sub-theme How Social Policies in Education Shape K-12 teacher Development in the Post-Conflict Context. Unpublished report. Royal University of Phnom Penh។

អនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅកាន់វិស័យកសិកម្មម្តងទៀត។ ក្នុងខណៈដែលវិស័យកសិកម្ម នៅតែជាសរសរស្តម្ភនៃសេដ្ឋកិច្ច និងជាគ្រឹះនៃសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ ការអប់រំ និងការស្រាវជ្រាវខាងកសិកម្មនៅមានកម្រិតតិចតួចបំផុត។ មាននិស្សិតតែប្រហែល ៦% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សាខាងផ្នែកកសិកម្ម ហើយមាននិស្សិតតែ ៣,៦៧% ប៉ុណ្ណោះ ដែលបានបញ្ចប់ការសិក្សាផ្នែកកសិកម្មក្នុងចំណោមនិស្សិតដែលបញ្ចប់ការសិក្សាទាំងអស់[16]។

នៅកម្រិតមធ្យមសិក្សា ការស្រាវជ្រាវមួយទៅលើសៀវភៅសិក្សាគោលគ្រប់កម្រិត ដោយផ្តោតលើចំណេះដឹង ជំនាញ និងឥរិយាបថបានរកឃើញថា ខ្លឹមសារដែលមាននៅក្នុងសៀវភៅគោលនេះ មានលក្ខណៈបែបពិពណ៌នា ហើយគ្មានភាពទាក់ទងអ្វីទាល់តែសោះទៅនឹងការប្រើប្រាស់ខ្លឹមសារទាំងនេះក្នុងការរួមចំណែកក្នុងសហគមន៍ និងជីវភាពរស់នៅទូទៅនៅកម្ពុជា។ លើសពីនេះទៀត ខ្លឹមសារដែលមាននៅក្នុងសៀវភៅគោលនេះ មានលក្ខណៈទូទៅ ដោយមិនឆ្លុះបញ្ចាំងពីបរិបទកម្ពុជាទាល់តែសោះ។ មុខវិជ្ជាទាក់ទងនឹងចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដូចជា សុខភាព ចំណីអាហារ បរិស្ថាន និងកសិកម្មមានខ្លឹមសារតិចតួចបំផុតដែលសំដៅដល់បរិបទកម្ពុជា[17]។

ការស្រាវជ្រាវនេះ ក៏បានរកឃើញផងដែរថា សៀវភៅគោលផ្នែកវិទ្យាសាស្ត្រសង្គមពុំបានភ្ជាប់ខ្លឹមសារទៅនឹងជីវិតរស់នៅក្នុងសហគមន៍នោះទេ ជាពិសេសទាក់ទងទៅនឹងការពង្រឹងអាកប្បកិរិយា និងឥរិយាបថដែលជាគន្លឹះនៃគុណភាព និងផលិតភាពការងារ ដូចជា ទំនុកចិត្ត ការលើកទឹកចិត្តខ្លួនឯង ការជឿជាក់លើសមត្ថភាពខ្លួនឯង ការដាក់វិន័យលើខ្លួនឯង ការតាំងចិត្តសម្រេចឲ្យបានលទ្ធផល ការចេះអត់ធ្មត់ ការប្រឹងប្រែង និងយកចិត្តទុកដាក់ និងជាមនុស្សរហ័សរហួន និងវ៉ៃឆ្លាត[18] ដែលទីផ្សារការងារកំពុងត្រូវការ។

តើអ្វីដែលជាមូលហេតុនៅពីក្រោយបទអន្តរាគមន៍ដែលរំលងបរិបទបែបនេះ? នៅកម្រិតអន្តរជាតិ មានការសិក្សាជាច្រើនអំពីបញ្ហានេះ[19]។ នៅកម្ពុជា ការសិក្សាអំពីបញ្ហានេះមានតិចតួចណាស់[20]។ នៅទីនេះ អនុញ្ញាតឲ្យខ្ញុំសង្ខេបយ៉ាងខ្លីដើម្បី

[16] យកចេញពី https://tradingeconomics.com/cambodia/, នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

[17] សូមមើល Un, L. et al. (2014). Upper Secondary School Curriculum Reform in Cambodia: Relevance for Employment. Unpublished report. Graduate Program in Education, Royal University of Phnom Penh

[18] ដដែល។

[19] សូមមើល Verger, A. (2012). "Framing and Selling Global Education Policy: The Promotion of Public–Private Partnerships for Education in Low-Income Contexts." Journal of Education Policy 27 (1): 109–130; Un, L. (2012). "A Comparative Study of Education and Development in Cambodia and Uganda from Their Civil Wars to the Present." Ph.D thesis submitted to the Faculty of Social and Behavioral Sciences, Amsterdam Institute for Social Science Research; Steiner-Khamsi, G. (2004). "Social Network Analysis and the Diffusion of Innovation Revisted: The Maris O' Rourke Effect in International Education." Paper presented at the Conference of the German Education Research Association, Zurich, March; Rappleye, J. (2011). "Catalyzing Educational Development or Institutionalizing International Influence? Donors, Civil Society, and Policy Formation in Nepal." Globalisation, Societies and Education 9 (1): 27–49; Edwards Jr., D. B. and I. Storen (2016). "The World Bank and Educational Assistance: History, Theory, Research." In Oxford Research Encyclopaedia of Education, edited by G. Noblit. Oxford: Oxford University Press; Edwards Jr., D. B. (2013). "International Processes of Educational Policy Formation: An Analytical Framework and the Case of Plan 2021 in El Salvador." Comparative Education Review 57 (1): 22–53; Easterly, W. (2006). The White Man's Burden: Why the West's Efforts to Aid the Rest Have Done So Much Ill and So Little Good. London: Oxford University Press; Dichter, T. W. (2003). Despite Good Intentions: Why Development Assistance to the Third World Has Failed. Boston: University of Massachusetts Press; Brehm, W. C., and I. Silova. (2010). "The Ignorant Donor: A Radical Re-imagination of International Aid, Development, and Education." Current Issues in Comparative Education 13 (1): 27–34។

[20] សូមមើល Jeremy Rappleye & Leang Un (2018). What Drives Failed Policy at the World Bank? An inside account of new aid modalities to higher education research, context, blame, and infallibility, Comparative Education, Vol. 54, issue 2, 250-274; អត្ថបទដែលត្រៀមនឹងបោះពុម្ពនាពេលខាងមុខ Un, Leang & Sok, Say "(Higher) Education Policy and Project Intervention in Cambodia: Its Development Discourse"។

យល់ពីមូលហេតុទាំងនេះ ហើយថាតើយើងត្រូវធ្វើបរិបទនីយកម្មបទអន្តរាគមន៍នាពេលខាងមុខដោយរបៀបណាដើម្បីពង្រឹងធនធានមនុស្សសម្រាប់ការកសាងជាតិ។

ការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាក្នុងអំឡុងដើមឆ្នាំ១៩៩០ ដោយអន្តរាគមន៍មកពីខាងក្រៅ បាននាំមកនូវលំហូរបទអន្តរាគមន៍ពីខាងក្រៅផងដែរ មិនមែនគ្រាន់តែជាហិរញ្ញវត្ថុប៉ុណ្ណោះទេ តែអ្វីដែលត្រូវធ្វើក៏បានហូរមកដែរតាមរយៈទីប្រឹក្សា ឬអ្នកជំនាញការ ដោយសារកម្ពុជា ជាប្រទេសដែលពឹងផ្អែកលើជំនួយបរទេស។ ការសិក្សាអំពីប្រសិទ្ធភាពជំនួយក្នុងឆ្នាំ២០០៤ បានរកឃើញថា ក្នុងចំណាយសរុបចំនួន ២៦៥លាន ដុល្លាសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១២,៧% ត្រូវបានចំណាយលើបុគ្គលិកអន្តរជាតិចំនួន ៧៥០ នាក់ ដើម្បីគាំទ្រការអនុវត្តន៍គម្រោង ឬកម្មវិធី។ ប្រសិនបើគិតពីគម្រោងផ្សេងទៀត ដែលមិនបានឆ្លើយកម្រងសំណួរ ការចំណាយទៅលើបុគ្គលិកអន្តរជាតិអាចកើនឡើងដល់ចន្លោះពី១៩,៥% ទៅ២៧,៣៤%[21]។ ការអង្កេតមួយផ្សេងទៀតបានមើលឃើញថា កម្ពុជាស្ទើរតែមិនដែលបដិសេធបុគ្គលិកជំនួយការបរទេសទាល់តែសោះ រាប់ទាំងអ្នកទាំងឡាយណាដែលសង្ស័យថាមិនចាំបាច់ និងមិនមានសមត្ថភាពធ្វើការ។

អ្វីដែលគ្រោះថ្នាក់ជាងនេះទៀត គឺថាជួនកាលទីប្រឹក្សា ឬអ្នកជំនាញការទាំងនេះ មិនដែលខ្វាយខ្វល់ពីកម្ពុជានោះទេ។ សម្រាប់ពួកគេ កម្ពុជាគ្រាន់តែជាទីផ្សារមួយតែប៉ុណ្ណោះ។ ជាភស្តុតាង គេមើលឃើញមានវត្តមានទីប្រឹក្សា ឬអ្នកជំនាញការនៅស្ទើរគ្រប់គម្រោងកម្មវិធី និងស្ទើរគ្រប់នាយកដ្ឋានជំនាញទាំងអស់។ រាល់គោលនយោបាយ និងគម្រោង ឬកម្មវិធីទាំងអស់ជាដំបូងសរសេរជាភាសាអង់គ្លេស រួចបកប្រែជាភាសាខ្មែរសម្រាប់ដាក់ឲ្យមានការពិគ្រោះយោបល់ តែគេឃើញមានការកែប្រែតិចតួចបំផុតលើកលែងតែអក្ខរាវិរុទ្ធ។ យុទ្ធវិធីរបស់រដ្ឋាភិបាល គឺព្យាយាមបង្កើនជំនួយគាំទ្រ ដោយមិនព្យាយាមជជែកច្រើនពីខ្លឹមសារគោលនយោបាយនោះទេ[22]។ ចំពោះទីប្រឹក្សា ឬអ្នកជំនាញការទាំងនេះ ដែលមកធ្វើការនៅកម្ពុជាក្នុងរយៈខ្លី មិនចេះភាសាខ្មែរ មិនស្គាល់វប្បធម៌ខ្មែរ អានតែអត្ថបទជាភាសាអង់គ្លេស ពិតជាមិនអាចមានសមត្ថភាពបង្កើតបទអន្តរាគមន៍ ដែលអាចឆ្លើយតបទៅនឹងបរិបទដ៏ស្មុគស្មាញនៃសង្គមកម្ពុជាបានទេ។ ពួកគេបានត្រឹមតែថតចម្លងគម្រោង ឬកម្មវិធីពីប្រទេសណាមួយ រួចយកមកឲ្យអនុវត្តនៅក្នុងប្រទេសកម្ពុជា។

ចាប់តាំងពីឆ្នាំ២០១៣មក គេឃើញមានការកើនឡើងនូវសមត្ថភាពក្នុងស្រុក រហូតមានការអះអាងដោយអ្នកជំនាញការបរទេស លោក Vin McNamara ដែលធ្វើការយូរអង្វែងនៅកម្ពុជាថា ចុងបញ្ចប់កម្ពុជាទទួលបានអធិបតេយ្យភាពក្នុងការបង្កើតគោលនយោបាយរបស់ខ្លួនហើយ[23]។ ការអង្កេតរបស់លោកអាចមានភាពត្រឹមត្រូវ ប្រសិនបើគេពិនិត្យលើការកើនឡើងនៃសមត្ថភាពក្នុងស្រុក។ នេះពីព្រោះថា ចាប់តាំងពីឆ្នាំ២០១០មក និស្សិតដែលបានបញ្ចប់ការសិក្សានៅបរទេសកាន់តែច្រើនឡើងបានត្រឡប់មកកម្ពុជាវិញ និងបានចូល

[21] សូមមើល Siddiqui, F., Strickler, C., and Vinde, P. (2004). Capacity building practices of Cambodia's development partners: A discussion paper. Government-donor partnership working group and CRDB/CDC។

[22] សូមមើល Sloper, D., & Moock, P. (1999). “The context of the National Education Action Plan Process”. In Sloped, D. (ed.). Higher education in Cambodia: the social and educational context for reconstruction. Bangkok: UNESCO។

[23] សូមមើល McNamara, V. (2013). Cambodia: from dependency to sovereignty – emerging nationalleadership. In Education in Southeast Asia. Bloomsbury, 23-45។

បម្រើការងាររដ្ឋ ហើយអ្នកខ្លះបានកាន់តំណែង និងតួនាទីសម្រេចចិត្តធំៗទៀតផង។

តាមពិត បទពិសោធន៍នៅកម្ពុជា គឺដូចជាអ្វីដែលលោក Stephen J. Ball កត់សម្គាល់ ដោយដឹង និងមានបំណង ឬដោយមិនដឹង និងមិនមានបំណងក៏ដោយ អ្នកដែលត្រឡប់មកពីបរទេសវិញភាគច្រើនស្វាគមន៍ខ្លឹមសារដូចដែលទីប្រឹក្សា ឬអ្នកជំនាញការបរទេសធ្លាប់បានប្រាប់ដែរ ជាពិសេសការបន្ទរវិចារណកិច្ចកំណែទម្រង់ទាំងនេះ ដែលគេជឿជាក់ថា បាននាំឲ្យប្រទេស និងតំបន់មួយចំនួនរីកចម្រើនដូចជា តៃវ៉ាន់ កូរ៉េខាងត្បូង សិង្ហបុរី និងម៉ាឡេស៊ី[24]។ល។ ហេតុនេះ អ្វីមួយដែលមិនគួរត្រូវបានមើលរំលងក្នុងការទទួលបានអធិបតេយ្យភាពនេះ គឺការគ្រាន់តែប្ដូររាងកាយពីបរទេសមកខ្មែរ តែនៅរក្សាខ្លឹមសារដដែល[25]។ ប៉ុន្តែរហូតមកទល់ពេលនេះ យើងមិនអាចសន្និដ្ឋានដោយមុតមាំទេថា ពួកគាត់ពិតជាមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើសខ្លឹមសារទាំងនោះទេ។ ការសិក្សាថ្មីៗ បានរកឃើញថា ទោះបីជារាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍពេលខ្លះមិនយល់ស្របគ្នាក៏ដោយ តែពួកគេបានក្លាយជាដៃគូយ៉ាងជិតស្និទ្ធ បង្កើតបានជាថាមពលរួមក្នុងការរុញកង់វិស័យណាមួយឲ្យទៅមុខ ក្នុងទម្រង់ជាការបង្កើតគោលនយោបាយ។ ប៉ុន្តែក្នុងការប្រតិបត្តិជាក់ស្ដែង ម្ចាស់ជំនួយនៅតែមានឥទ្ធិពលក្នុងការសម្រេចចិត្តជាង ឧទាហរណ៍ក្នុងការជ្រើសរើសផ្នែកណាមួយដែលនឹងត្រូវវិនិយោគមុន ពីព្រោះម្ចាស់ជំនួយអាងថា ខ្លួនមានលុយ និងមានឯកទេសជាង[26] ជាពិសេសតាមរយៈមេរៀន ឬបទពិសោធន៍ល្អៗ ដែលបានអនុវត្តនៅតាមបណ្ដាប្រទេសផ្សេងៗ។ នៅក្នុងន័យនេះ អ្វីដែលជាអធិបតេយ្យភាពនៃការធ្វើគោលនយោបាយ និងបទអន្តរាគមន៍ដែលយើងឃើញ គឺមិនមែនអំពីអ្វីជាគោលបំណងនៃបទអន្តរាគមន៍នោះទេ ប៉ុន្តែយ៉ាងច្រើនណាស់គ្រាន់តែពីរបៀបអនុវត្តបទអន្តរាគមន៍ ឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលតែប៉ុណ្ណោះ។ និយាយម្យ៉ាងវិញទៀត គេសង្កេតឃើញ "មានកំណែទម្រង់ ប៉ុន្តែមិនមែនកំណែខ្លឹមសារ"។

## ❖ ត្រឡប់ទៅកាន់ស្ថានភាពជំងឺកូវីដ១៩ វិញ

ឥឡូវនេះ អនុញ្ញាតឲ្យខ្ញុំត្រឡប់មកពិភាក្សាអំពីបញ្ហាជំងឺកូវីដ១៩ វិញម្ដង។ ក្នុងស្ថានភាពនៃការមិនអាចដំណើរការបានដោយមុខទល់មុខគ្នា ក្នុងវិស័យអប់រំ ការសិក្សារៀនសូត្រតាមបែបបច្ចេកវិទ្យាទំនើប ដោយប្រើប្រព័ន្ធផ្សេងៗ តាមរយៈអ៊ីនធឺណិតបាន និងកំពុងលើកកម្ពស់ រហូតដល់មានការពិភាក្សាគ្នាថា តើត្រូវប្រើប្រាស់ប្រព័ន្ធបែបនេះដោយរបៀបណា នៅពេលដែលបញ្ហាជំងឺកូវីដ១៩បានបញ្ចប់ថែមទៀតផង។ សម្រាប់ខ្ញុំ នេះគ្រាន់តែជាប្រភេទនៃកំណែទម្រង់ថ្មីមួយបែបទៀតតែប៉ុណ្ណោះ។ នៅទីនេះ អនុញ្ញាតឲ្យខ្ញុំពិភាក្សាលើពីរចំណុច។ ការសិក្សារៀនសូត្រដំណើរការដោយមុខទល់មុខគ្នាក្នុងរយៈពេលប្រហែល៣០ឆ្នាំកន្លងមក បាននាំមកនូវអ្វីមួយដែលរបាយការណ៍ខាងលើអះអាងថា មានវិបត្តិក្នុងការរៀនសូត្រ។ មានន័យថា កូនសិស្សមិនបានចេះដឹងដូចការរំពឹងទុក។ តើទម្រង់ថ្មីនៃការសិក្សាតាមបែបបច្ចេកវិទ្យាទំនើប ដោយប្រើប្រព័ន្ធផ្សេងៗ តាមរយៈអ៊ីនធឺណិតអាចធានាបានទេថា សិស្ស ឬនិស្សិតពិតជាចេះដូចការរំពឹងទុក? ហើយឧបមាថា ជាសំណាងល្អ សិស្ស ឬនិស្សិតពិតជាចេះដូចការរំពឹងទុកមែន តើខ្លឹមសារដែលមានស្រាប់ ដែលមិន

---

[24] សូមមើល Ball, J. S. (2012). Global education Inc: new policy networks and the neo-liberal imaginary. Abingdon: Routledge។

[25] និយាយបែបនេះមិនមែនមានន័យថា គ្រប់ខ្លឹមសារដែលបរទេសនិយាយទាំងអស់សុទ្ធតែជារឿងមិនល្អ និងមិនត្រឹមត្រូវនោះទេ។

[26] សូមមើល Sam, C. (2016). Higher Education in Transition: Stakeholder involvement and challenges for academic institution in Cambodia (Ph.D. thesis). VU University Amsterdam។

បាននាំកម្ពុជាទៅដល់ការកសាងសេដ្ឋកិច្ចមួយដែលរឹងមាំ ដូចដែលបានពិភាក្សាខាងលើ អាចបំលែងខ្លួនចេញជាអ្វីផ្សេងទេ ដើម្បីបណ្តុះគ្រាប់ពូជសិស្ស ឬនិស្សិតឲ្យចេះកសាងសេដ្ឋកិច្ចកម្ពុជាមួយដ៏រឹងមាំ ដែលជាគ្រឹះនៃការកសាងជាតិ? តើវាអាចកើតឡើងដោយរបៀបណា?

### ❖ យោបល់ចុងក្រោយ

គ្មានប្រទេសណាមួយ ដែលមិនរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩នោះទេ សូម្បីប្រទេសដែលមានធនធានច្រើនហួសហេតុ និងមានបច្ចេកវិទ្យាខ្ពស់ ដូចជាសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អ៊ីតាលី បារាំង ជប៉ុន សិង្ហបុរី និងចិនជាដើម។ រហូតមកទល់ពេលនេះ អ្វីដែលកើតមាននៅកម្ពុជា ប្រសិនបើយើងប្រៀបធៀបជាមួយប្រទេសធំៗខាងលើ កម្ពុជាពិតជាចាត់ចែងបានល្អណាស់ហើយ។ អ្វីដែលសំខាន់ គឺការបន្តយកចិត្តទុកដាក់បែបនេះបន្តទៀត។ ខ្ញុំជឿជាក់ថា វាគ្មានដំណោះស្រាយណាមួយជាក់លាក់ចំពោះស្ថានភាពដែលមិនជាក់លាក់នោះទេ យន្តការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ១៩ នឹងប្រែប្រួលទៅតាមកាលៈទេសៈនោះ។ ប៉ុន្តែតាមរយៈធម្មជាតិនៃការរីករាលដាលនៃជំងឺនេះ អ្វីមួយដែលច្បាស់ជាងគេ គឺការចូលរួមរបស់ពលរដ្ឋទាំងអស់គ្នាក្នុងការបង្អាក់ការរីករាលដាលនៃជំងឺកូវីដ១៩ តាមរយៈការមិនចម្លងទៅអ្នកដទៃ និងការមិនចង់ឆ្លងពីអ្នកដទៃ ហើយយុទ្ធសាស្ត្រដែលច្បាស់លាស់បំផុត និងចំណាយធនធានតិចបំផុតនោះគឺ "ការនៅឲ្យឆ្ងាយពីទំនាក់ទំនងក្នុងសង្គមមនុស្ស"។ តែអ្វីដែលសំខាន់ជាងនេះ គឺការមិនអនុញ្ញាតឲ្យមានចលាចលសង្គមណាមួយកើតឡើង ដោយយកលេសពីការចាត់ចែងបញ្ហាជំងឺកូវីដ១៩មិនបានល្អនោះទេ។ ម្នាក់ៗត្រូវតែគិតថា ភាពច្របូកច្របល់ដែលអាចកើតឡើងក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ១៩ គ្មានតម្លៃស្មើនឹងសន្តិភាពពេញលេញ ដែលទទួលបានយ៉ាងពិបាកនោះទេ ការសម្រេចបានសន្តិភាពនេះក្នុងឆ្នាំ១៩៩៨ វាលំបាកជាងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩នេះទៅទៀត។ ហើយអ្វីដែលសំខាន់ជាងនេះទៅទៀត គឺកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ១៩ ពីព្រោះថា ចង់ឬមិនចង់ សណ្តាប់ធ្នាប់សង្គម និងពិភពលោកទាំងមូលនឹងមានការប្រែប្រួល ដោយសារការប្រកួតប្រជែងថ្មីដែលជាបទពិសោធន៍នៃការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ១៩។ នៅទីនេះ ការអប់រំ គឺជាគន្លឹះមួយដែលនាំឲ្យកម្ពុជាអាចឈរជើងដោយរឹងមាំ នៅពេលដែលជំងឺកូវីដ១៩ ត្រូវបានលុបបំបាត់។ ការបិទទ្វារមិនសូវទាក់ទងជាមួយបរទេសក្នុងពេលនេះ ផ្តល់ជា "កាលានុវត្តភាពពេជ្រ" សម្រាប់កម្ពុជាក្នុងការសញ្ជឹងគិតឡើងវិញអំពីខ្លឹមសារអប់រំ ដែលអនុញ្ញាតឲ្យកម្ពុជាបណ្តុះគ្រាប់ពូជថ្មីសម្រាប់ការកសាងជាតិមួយ ប្រកបដោយមោទនភាពពិតប្រាកដ។

*អ្នកនិពន្ធជ្រើសយកការប្រើនិទ្ទេសជើងទំព័រសម្រាប់ឯកសារយោង។*


Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center